# ធនធានដែលមានប្រយោជន៍សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សា

**អ្នកមិនមែនមានតែម្នាក់ឯងនោះទេ សូមទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទបន្ទាន់ទាំងឡាយខាងក្រោមនេះ។**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ទំនងជានឹងមានគ្រោះថ្នាក់ភ្លាមៗនោះ សូមទូរស័ព្ទទៅកាន់លេខ 911។

▼ ទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ ● ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទ ■ ទាក់ទងទៅនឹងការជួញដូរមនុស្ស

## 211 សម្រាប់ខោនធី LOS ANGELES (211 LOS ANGELES COUNTY)

**លេខទូរស័ព្ទ៖ 2-1-1**

គេហទំព័រទូទៅ៖ http://www.211la.org/

គេហទំព័រសេវាកម្ម 211 សម្រាប់យុវជន៖ https://211la.org/resources/subcategory/youth-services

211 LA គឺជាប្រភពសំខាន់បំផុតក្នុងការផ្តល់ព័ត៌មាន និងការបញ្ជូនឈ្មោះសម្រាប់សេវាកម្មទាំងអស់ផ្នែកសុខភាព និងមនុស្សជាតិនៅក្នុងខោនធី LA។ ទីប្រឹក្សាផ្នែកធនធាននៅក្នុងសហគមន៍ដែលបានទទួលការបង្ហាត់ត្រឹមត្រូវ (Trained Community Resource Advisors) ទាំងឡាយគឺអាចរកបាន 24 ម៉ោងក្នុងមួយថ្ងៃ ដើម្បីផ្តល់ជំនួយសម្រាប់ស្ថានភាពណាមួយ ឬនៅពេលណាមួយក៏ដោយ។

## បណ្តាញទូរស័ព្ទបន្ទាន់សម្រាប់រាយការណ៍អំពីការបំពាន របស់ផ្នែកសេវាកម្មការពារមនុស្សពេញវ័យនៃខោនធី LA (ADULT PROTECTIVE SERVICES ABUSE REPORT HOTLINE, LA COUNTY) ▼ ●

**លេខទូរស័ព្ទ៖ (877) 477-3646**

គេហទំព័រ៖ https://ad.lacounty.gov/

កម្មវិធីមួយដែលមានផ្តល់សេវាកម្មជូន 24 ម៉ោងក្នុងមួយថ្ងៃ ហើយដែលទុកសម្រាប់ការស៊ើបអង្កេតទៅលើស្ថានភាពទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងមនុស្សចាស់ (ដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ) និងមនុស្សពេញវ័យក្នុងបន្ទុក (ដែលមានអាយុចាប់ពី 18 ទៅ 64 ឆ្នាំ ហើយដែលមានបញ្ហាផ្នែកផ្លូវកាយ និងផ្នែកផ្លូវចិត្ត) ដែលបានរាយការណ៍ថាអាចទទួលរងគ្រោះថ្នាក់ដោយការបំពានផ្លូវកាយ ការបំពានផ្លូវភេទឬការបំពានផ្នែកប្រាក់កាស ការដាក់ឱ្យនៅដាច់ដោយឡែក ការធ្វេសប្រហែស ឬក៏ការធ្វេសប្រហែសដោយខ្លួនពួកគេផ្ទាល់ ផងដែរ។

## បណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ការបំពានទៅលើកុមារថ្នាក់ជាតិ របស់អង្គការ CHILDHELP (CHILDHELP NATIONAL CHILD ABUSE HOTLINE) ▼ ● ■

**ទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅកាន់លេខ៖ 800-422-4453**

**លេខសម្រាប់នៅក្នុងខោនធី LA៖ 1-800-540-4000**

គេហទំព័រ៖ https://www.childhelp.org/hotline/

ទុកសម្រាប់ការទប់ស្កាត់ការបំពានទៅលើកុមារ។ បណ្តាញទូរស័ព្ទដែលអាចប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃនេះផ្តល់នូវការអន្តរាគមន៍ក្នុងពេលមានវិបត្តិ ហើយនិងការបញ្ជូនឈ្មោះទៅកាន់សេវាកម្មសង្គម ព្រមទាំងធនធានជំនួយផ្សេងៗនៅក្នុងតំបន់។

## បណ្តាញទូរស័ព្ទបន្ទាន់ របស់អង្គការក្រុមចម្រុះដើម្បីកម្ចាត់ភាពជាទាសករ និងការជួញដូរមនុស្ស (CAST) (COALITION TO ABOLISH SLAVERY AND TRAFFICKING [CAST] HOTLINE) ■

**លេខទូរស័ព្ទ៖ (888) 539-2373**

**ឬលេខទូរស័ព្ទ៖ (888) KEY-2-FREE**

គេហទំព័រ https://www.castla.org/

កម្មវិធីមួយដែលមានផ្តល់សេវាកម្មជូន 24 ម៉ោងក្នុងមួយថ្ងៃ ហើយដែលទុកសម្រាប់ការជួយដល់មនុស្សទាំងឡាយដែលរងគ្រោះដោយសារការជួញដូរ សម្រាប់គោលបំណងឱ្យធ្វើការងារទាំងបង្ខំ និងការអនុវត្តន៍នានាដែលប្រៀបដូចជាទាសករ ហើយដែលរួមមានទាំងការជួញដូរផ្លូវភេទ ផងដែរ។ កម្មវិធីនេះផ្តល់សេវាកម្មផ្នែកផ្លូវច្បាប់ សេវាកម្មផ្នែកសុខភាពផ្លូវចិត្ត និងទីស្នាក់អាស្រ័យជូនដល់បុគ្គលទាំងនោះ ក៏ដូចជាការភ្ជាប់បុគ្គលទាំងនោះទៅកាន់សេវាកម្មខាងលើនេះផងដែរ។

## ផ្នែកការការពារកុមារ របស់នាយកដ្ឋានសេវាកម្មសម្រាប់កុមារនិងក្រុមគ្រួសារនៃខោនធី LA (LA COUNTY DEPARTMENT OF CHILDREN AND FAMILY SERVICES - CHILD PROTECTION) ▼ ● ■

**លេខទូរស័ព្ទ៖ (800) 540-4000**

**លេខទូរស័ព្ទសម្រាប់នៅក្រៅរដ្ឋ CALIFORNIA៖ 213-639-4500**

**លេខទូរស័ព្ទសម្រាប់អ្នកមានបញ្ហាស្តាប់មិនសូវឮ (TDD)៖ 800-272-6699**

គេហទំព័រ៖ https://dcfs.lacounty.gov/

ដើម្បីធ្វើការរាយការណ៍៖ http://reportchildabusela.org

សម្រាប់ការរាយការណ៍អំពីការបំពានលើកុមារតាមការបញ្ជារបស់ច្បាប់ និងការរាយការណ៍ជាសាធារណៈ ដែលរួមមានទាំង

# ធនធានដែលមានប្រយោជន៍សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សា

**អ្នកមិនមែនមានតែម្នាក់ឯងនោះទេ សូមទូរស័ព្ទទៅកាន់បណ្ដាញទូរស័ព្ទបន្ទាន់ទាំងឡាយខាងក្រោមនេះ។**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ទំនងជានឹងមានគ្រោះថ្នាក់ភ្លាមៗនោះ សូមទូរស័ព្ទទៅកាន់លេខ 911។

▼ ទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ ● ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទ ■ ទាក់ទងទៅនឹងការជួញដូរមនុស្ស

ការកេងចំណេញផ្នែកផ្លូវភេទជាលក្ខណៈជំនួញចំពោះកុមារ (commercial sexual exploitation of children/CSEC) ផងដែរ ហើយមានសម្រាប់ប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍។

## បណ្ដាញទូរស័ព្ទបន្ទាន់ ACCESS របស់នាយកដ្ឋានសុខភាពផ្លូវចិត្តនៃខោនធី LA (LA COUNTY DEPARTMENT OF MENTAL HEALTH ACCESS HOTLINE)

**លេខទូរស័ព្ទ៖ (800) 854-7771**

គេហទំព័រ៖ https://dmh.lacounty.gov/our-services/disaster-services/access-hotline/

ចំណុចចាប់ផ្ដើមសម្រាប់ទទួលបានសេវាកម្មផ្នែកសុខភាពផ្លូវចិត្តនៅក្នុងខោនធី LA ដែលរួមមានក្រុមសម្រាប់ធ្វើការវាយតម្លៃលើវិបត្តិ (crisis evaluation teams) ព័ត៌មាននិងការបញ្ជូនឈ្មោះ សេវាកម្មផ្នែកអ្នកបកប្រែផ្ទាល់មាត់ ហើយនិងមធ្យោបាយដឹកជញ្ជូនអ្នកជំងឺ ដែលមានសម្រាប់ប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍។ សូមទូរស័ព្ទទៅ ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវការសេវាកម្មផ្នែកសុខភាពផ្លូវចិត្ត។

## បណ្ដាញទូរស័ព្ទបន្ទាន់នៃខោនធី LA ផ្នែកអំពើហិង្សាក្នុងគ្រួសារ (LA COUNTY DOMESTIC VIOLENCE HOTLINE) ▼

**លេខទូរស័ព្ទ៖ (800) 978-3600**
**បណ្ដាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិ៖ 1-800-799-7233**
**សារជាអក្សរ៖ ផ្ញើសារជាអក្សរ "START" ទៅកាន់លេខ 88788**

មានផ្ដល់ជំនួយ 24 ម៉ោងក្នុងមួយថ្ងៃជូនដល់អ្នកធ្លាប់ជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដោយការភ្ជាប់ទំនាក់ទំនងអ្នកទាំងនោះទៅកាន់ទីស្នាក់អាស្រ័យនៅក្នុងតំបន់ និងធនធានជំនួយផ្សេងៗទៀត ផងដែរ។

## បណ្ដាញទូរស័ព្ទបន្ទាន់សម្រាប់ការចាប់រំលោភ និងការវាយដំ (LA RAPE AND BATTERING HOTLINE) ▼ ●

**លេខទូរស័ព្ទសម្រាប់តំបន់ LOS ANGELES កណ្ដាល (CENTRAL LOS ANGELES)៖ 213-626-3393**
**លេខទូរស័ព្ទសម្រាប់តំបន់ LOS ANGELES ខាងត្បូង (SOUTH LOS ANGELES)៖ 310-392-8381**
**លេខទូរស័ព្ទសម្រាប់តំបន់ SAN GABRIEL VALLEY ខាងលិច (WEST SAN GABRIEL VALLEY)៖ 626-793-3385**
**លេខទូរស័ព្ទជាវីដេអូសម្រាប់តំបន់ LA (ភាសាកាយវិការអាមេរិក/ASL)៖ 213-785-2684 ឬ 213-785-2749**
**លេខទូរស័ព្ទជាវីដេអូសម្រាប់តំបន់ PASADENA (ភាសាកាយវិការអាមេរិក/ASL)៖ 626-243-7972**

គេហទំព័រ៖ https://www.peaceoverviolence.org/hotlines

ធនធានដែលមានរក្សាការសម្ងាត់ ហើយមិនមានការវាយតម្លៃទុកជាមុនមួយ និងមានផ្ដល់ជូន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍ ដែលមានបុគ្គលិក និងអ្នកស្ម័គ្រចិត្តសម្រាប់ផ្ដល់ការគាំទ្រផ្នែកអារម្មណ៍ ការគាំទ្រមតិ ហើយនិងផ្ដល់ព័ត៌មាននិងការបញ្ជូលឈ្មោះ ផងដែរ។

## គម្រោងបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ របស់មជ្ឈមណ្ឌលសម្រាប់អ្នក LGBT (LGBT CENTER STOP DOMESTIC VIOLENCE PROJECT) ▼

**លេខទូរស័ព្ទ៖ (323) 860-5806**

គេហទំព័រ៖ https://lalgbtcenter.org/services/survivor-services/domestic-violence-sexual-assault-and-stalking/

មានផ្ដល់សេវាកម្មផ្សេងៗដោយអ្នកឯកទេសផ្នែកអំពើហិង្សាក្នុងគ្រួសារសម្រាប់អ្នក LGBT (Lesbian [ស្រីស្រឡាញ់ស្រី], Gay [ប្រុសស្រឡាញ់ប្រុស], Bisexual [ស្រឡាញ់ទាំងពីរភេទ] និង Transgender [ប្ដូរភេទខុសពីកំណើត]) ដែលរួមមានទាំងអ្នកផ្ដល់ប្រឹក្សាទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារដែលមានការបញ្ជាក់ត្រឹមត្រូវ ហើយនិងអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត និងមេធាវីដែលបានទទួលការបង្ហាត់ត្រឹមត្រូវក្នុងផ្នែកបញ្ហានានាទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសាររបស់អ្នក LGBT ផងដែរ។

## បណ្ដាញទូរស័ព្ទបន្ទាន់ របស់អង្គការ LOVE IS RESPECT (LOVE IS RESPECT HOTLINE) ▼ ● ■

**លេខទូរស័ព្ទ៖ (866) 331-9474**
**ផ្ញើសារជាអក្សរ "LOVEIS" ទៅកាន់លេខ 22522**

គេហទំព័រ៖ https://www.loveisrespect.org/

---

# ធនធានដែលមានប្រយោជន៍សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សា

**អ្នកមិនមែនមានតែម្នាក់ឯងនោះទេ សូមទូរស័ព្ទទៅកាន់បណ្ដាញទូរស័ព្ទបន្ទាន់ទាំងឡាយខាងក្រោមនេះ។**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ទំនងជានឹងមានគ្រោះថ្នាក់ភ្លាមៗនោះ សូមទូរស័ព្ទទៅកាន់លេខ 911។

ទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ | ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទ | ទាក់ទងទៅនឹងការជួញដូរមនុស្ស

មានសម្រាប់ប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍ ដើម្បីផ្ដល់ការអប់រំ ការគាំទ្រ និងការគាំទ្រមតិដល់យុវជន និងមនុស្សពេញវ័យនៅក្មេង ក៏ដូចជាមិត្តភក្តិនិងក្រុមគ្រួសាររបស់ពួកគេដែលមានការខ្វល់ខ្វាយ ហើយដែលអាចនឹងមានសំណួរ ឬការព្រួយបារម្ភផ្សេងៗអំពីការទំនាក់ទំនងស្នេហារបស់ពួកគេ ផងដែរ។

### អង្គការបុរសធ្លាប់ជាជនរងគ្រោះ
### (MALE SURVIVOR)

**មិនមានបណ្ដាញទូរស័ព្ទបន្ទាន់ទេ មានតែគេហទំព័រប៉ុណ្ណោះ**

គេហទំព័រ៖ https://www.malesurvivor.org/

មានផ្ដល់ព័ត៌មានដល់បុរសធ្លាប់ជាជនរងគ្រោះដោយសារការបំពានផ្លូវភេទ ដែលរួមមានទាំងតំណភ្ជាប់គេហទំព័រទៅកាន់សេវាកម្មដោះស្រាយវិបត្តិ និងអ្នកព្យាបាលដោយមិនប្រើប្រាស់ថ្នាំពេទ្យ (ដូចជាអ្នកព្យាបាលចិត្តសាស្ត្រ) ផងដែរ។

### បណ្ដាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិផ្នែកអំពើហិង្សាក្នុងគ្រួសារ
### (NATIONAL DOMESTIC VIOLENCE HOTLINE)

**ការជជែកដោយផ្ទាល់៖ (800) 799- SAFE (7233) | (800) 787- 3224 (លេខសម្រាប់អ្នកថ្លង់/TTY)**

**ផ្ញើសារជាអក្សរ "START" ទៅកាន់លេខ 88788**

គេហទំព័រ៖ https://www.thehotline.org/

បណ្ដាញទូរស័ព្ទបន្ទាន់ដែលមានរក្សាការសម្ងាត់ ហើយអាចប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍នេះគឺមានសម្រាប់អ្នកធ្លាប់ជាជនរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្នេហា (intimate partner violence) មិត្តភក្តិនិងក្រុមគ្រួសាររបស់ពួកគេ ហើយនិងបុគ្គលដែលកំពុងបង្កគ្រោះថ្នាក់ទៅដល់ដៃគូរបស់ពួកគេ (ឬមានអារម្មណ៍ថាពួកគេទំនងជាអាចនឹងធ្វើដូចនេះ)។ បណ្ដាញទូរស័ព្ទបន្ទាន់នេះអាចភ្ជាប់ទំនាក់ទំនងអ្នកទៅកាន់សេវាកម្មផ្សេងៗក្នុងតំបន់បាន។

### បណ្ដាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិផ្នែកការជួញដូរមនុស្ស
### (NATIONAL HUMAN TRAFFICKING HOTLINE)

**លេខទូរស័ព្ទ៖ (888) 373-7888**

**ជម្រើសសម្រាប់ផ្ញើសារជាអក្សរ៖ 233733**

**លេខសម្រាប់អ្នកថ្លង់ (TTY)៖ 711**

**អ៊ីម៉េល៖ help@humantraffickinghotline.org**

គេហទំព័រ៖ https://humantraffickinghotline.org/

បណ្ដាញទូរស័ព្ទបន្ទាន់ និងមជ្ឈមណ្ឌលផ្ដល់ធនធានថ្នាក់ជាតិប្រឆាំងនឹងការជួញដូរមនុស្ស ដែលមានផ្ដល់សេវាកម្មជូន 24 ម៉ោងក្នុងមួយថ្ងៃ ហើយដោយមានជម្រើសជាការជជែកដោយផ្ទាល់ និងការផ្ញើសារជាអក្សរ ផងដែរ។ បណ្ដាញទូរស័ព្ទបន្ទាន់នេះផ្ដល់សេវាកម្ម និងជំនួយសម្រាប់បុគ្គលទាំងឡាយដែលបានជួបប្រទះនឹងការជួញដូរមនុស្សដោយផ្ទាល់។

### បណ្ដាញទូរស័ព្ទ LIFELINE ទាក់ទងទៅនឹងការធ្វើអត្តឃាត និងវិបត្តិ 988
### (988 SUICIDE AND CRISIS LIFELINE)

**លេខទូរស័ព្ទ៖ 988**

គេហទំព័រ៖ https://988lifeline.org

មានផ្ដល់ជំនួយដែលមិនគិតថ្លៃ ហើយរក្សាការសម្ងាត់ និងអាចប្រើប្រាស់បាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្ដាហ៍សម្រាប់អ្នកដែលមានទុក្ខព្រួយខ្លាំង ក៏ដូចជាធនធានទាក់ទងទៅនឹងការទប់ស្កាត់បញ្ហានិងវិបត្តិសម្រាប់អ្នក ឬមនុស្សជាទីស្រឡាញ់របស់អ្នក ហើយនិងគំរូអនុវត្តន៍ល្អបំផុតសម្រាប់អ្នកជំនាញទាំងឡាយ ផងដែរ។

### បណ្ដាញទូរស័ព្ទបន្ទាន់របស់អង្គការបណ្ដាញថ្នាក់ជាតិ ទាក់ទងទៅនឹងការចាប់រំលោភ ការបំពាន និងសន្ធការ (ការខូចនឹងគ្នារវាងសាច់សាលោហិត) (RAINN)
### (RAPE, ABUSE & INCEST NATIONAL NETWORK [RAINN] HOTLINE)

**លេខទូរស័ព្ទ៖ (800) 656-HOPE**

គេហទំព័រ៖ https://www.rainn.org/

បណ្ដាញទូរស័ព្ទដែលមានរក្សាការសម្ងាត់ ហើយដែលផ្ដល់សេវាកម្មជូន 24 ម៉ោងក្នុងមួយថ្ងៃនេះ ដាក់បញ្ជូនអ្នកដែលទូរស័ព្ទទៅឱ្យជួបជាមួយអ្នកផ្ដល់សេវាកម្មដោះស្រាយបញ្ហាការបំពានផ្លូវភេទ ហើយនិងផ្ដល់ធនធានផ្សេងៗក្នុងតំបន់ជូន

# ធនធានដែលមានប្រយោជន៍សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សា

**អ្នកមិនមែនមានតែម្នាក់ឯងនោះទេ សូមទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទបន្ទាន់ទាំងឡាយខាងក្រោមនេះ។**

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ទំនងជានឹងមានគ្រោះថ្នាក់ភ្លាមៗនោះ សូមទូរស័ព្ទទៅកាន់លេខ 911។

▼ ទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ ● ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទ ■ ទាក់ទងទៅនឹងការជួញដូរមនុស្ស

ដល់ជនរងគ្រោះដោយសារការបំពានផ្លូវភេទ ដែលអាចជួយក្នុងជំហានបន្តបន្ទាប់ទៀតឆ្ពោះទៅកាន់ការព្យាបាល និងការជាសះស្បើយឡើងវិញ ផងដែរ។

### បណ្តាញទូរស័ព្ទជំនួយសម្រាប់សេវាកម្មទាក់ទងទៅនឹងការប្រើប្រាស់សារធាតុញៀននៃខោនធី LA (SUBSTANCE ABUSE SERVICE HELPLINE, LA COUNTY)

**លេខទូរស័ព្ទ៖ (844) 804-7500**

គេហទំព័រ៖ http://publichealth.lacounty.gov/sapc/

ផ្តល់ជូនសេវាកម្មគ្រប់ប្រភេទទាក់ទងទៅនឹងជំនួយក្នុងការទប់ស្កាត់ ការព្យាបាល និងការជាសះស្បើយឡើងវិញ ដើម្បីកាត់បន្ថយឥទ្ធិពលនៃការប្រើប្រាស់សារធាតុញៀន ឬការប្រើប្រាស់សារធាតុញៀនហួសកម្រិត និងការញៀនសារធាតុនានា នៅក្នុងខោនធី Los Angeles ដែលមានបម្រើការជូន 24 ម៉ោងក្នុងមួយថ្ងៃ។

### បណ្តាញទូរស័ព្ទជំនួយផ្នែកសុខភាពផ្លូវចិត្តសម្រាប់យុវជន (TEENLINE)

**លេខទូរស័ព្ទ៖ 800-852-8336 (ចាប់ពីម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់ សម្រាប់រដ្ឋប៉ែកខាងលិចសហរដ្ឋអាមេរិក) ឬផ្ញើសារជាអក្សរ "TEEN" ទៅកាន់លេខ 839863 (ចាប់ពីម៉ោង 6 ល្ងាច ដល់ម៉ោង 9 យប់ សម្រាប់រដ្ឋប៉ែកខាងលិចសហរដ្ឋអាមេរិក) (ដូចជារដ្ឋ California)**

គេហទំព័រ៖ https://www.teenline.org/

បណ្តាញទូរស័ព្ទជំនួយពីយុវជនមានវ័យប្រហាក់ប្រហែលគ្នាដែលមានរក្សាការសម្ងាត់នេះមានផ្តល់ដំបូន្មាន ការបញ្ជូនឈ្មោះ ហើយនិងការអន្តរាគមន៍និងការទប់ស្កាត់មិនឱ្យមានវិបត្តិ ផងដែរ។